Care1st HEALTH PLAN

Yes, it is all about you.

# សិទ្ធិ និងការទទួលខុសត្រូវ របស់សមាជិក

## តើសិទ្ធិការថែទាំសុខភាពរបស់ មានអ្វីខ្លះ?

### អ្នកមានសិទ្ធិត្រូវស្គាល់

- ស្គាល់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នក ។
- ស្គាល់អំពីសេវា គ្រូពេទ្យ និងអ្នកឯកទេសរបស់យើង ហើយនិងបានជំរាប នៅពេលណាគ្រូពេទ្យរបស់អ្នក លែងមានកុងត្រាជាមួយនឹង Care1st Health Plan ទៀត ។
- ស្គាល់អំពីអ្នកថែទាំផ្សេងទៀតរបស់យើង ។
- អាចមើលកំណត់ត្រាសុខភាពរបស់អ្នក ។  អ្នកត្រូវតែប្រព្រឹត្តតាមច្បាប់រដ្ឋ និងរដ្ឋបាលសហព័ន្ធ ដែលជាប់ទាក់ទង ។
- អាចនិយាយដោយស្មោះត្រង់ ជាមួយនឹងគ្រូពេទ្យរបស់អ្នក អំពីជំរើសការព្យាបាល សំរាប់លក្ខណៈសុខភាពរបស់អ្នក ទោះជាមានតម្លៃប៉ុន្មាន មានឬឥតមានការរ៉ាប់រងអត្ថប្រយោជន៍ ក៏ដោយ ។

### អ្នកមានសិទ្ធិត្រូវបានគេប្រព្រឹត្តមកលើយ៉ាងល្អ

- ត្រូវបានគេប្រព្រឹត្តមកលើដោយគោរពជានិច្ច ។
- ត្រូវបានគេរក្សាភាពឯកជនរបស់អ្នកយ៉ាងគង់វង្ស ដោយនរណាម្នាក់នៅក្នុងគំរោងសុខភាពរបស់យើង ។
- ដឹងថាយើងរក្សាព័ត៌មានទាំងអស់របស់អ្នក ទុកជាសំងាត់ ។

### អ្នកមានសិទ្ធិទទួលបន្ទុក ក្នុងការថែទាំសុខភាពរបស់អ្នក

- ជ្រើសរើសគ្រូពេទ្យជាបឋមរបស់អ្នក ។
- ប្រកែកមិនទទួលការថែទាំ ពីគ្រូពេទ្យជាបឋមរបស់អ្នក ឬពីអ្នកថែទាំផ្សេងៗទៀត ។
- អាចធ្វើការជ្រើសរើស អំពីការថែទាំសុខភាពរបស់អ្នក ។
- ធ្វើសំបុត្របណ្តាំពេលនៅរស់ (ក៏ហៅថា សេចក្តីបង្គាប់ទុកជាមុនដែរ) ។
- បញ្ចេញសំឡេងការត្អូញត្អែរ ឬតវ៉ា អំពី Care1st ឬការថែទាំដែលយើងផ្តល់ រួមមានទាំងសិទ្ធិប្តឹងសារទុក្ខ(ការសើរើសេចក្តីទុក្ខ) បើសិនជាអ្នកមិនបានទទួលសេវា ជាភាសាដែលអ្នកស្នើទេ ។

### អ្នកមានសិទ្ធិទទួលសេវា យ៉ាងច្រើនក្រៃលែង

- ទទួលសេវាការរៀបចំគំរោងការគ្រួសារ ។
- ទទួលសេវាការថែទាំសុខភាពជាបន្ទាន់ ។
- ទទួលសេវាការយល់ព្រមពីអនីតិជន ។
- ត្រូវបានព្យាបាលកាមរោគ (STD) ។
- ទទួលការថែទាំនៅគ្រាអាសន្ន នៅក្រៅបណ្តាញរបស់យើង ។
- ទទួលការថែទាំសុខភាព ពីមជ្ឈមណ្ឌលសុខភាពដែលរដ្ឋបាលសហព័ន្ធទទួលស្គាល់ (FQHC) ។
- ទទួលការថែទាំសុខភាព នៅមជ្ឈមណ្ឌលសុខភាពឥណ្ឌាន ។
- ទទួលមិតីពីរ ។
- ទទួលសេវាពីអ្នកបកប្រែ ដោយឥតអស់ថ្លៃអ្វីសោះ ។  ការនេះរួមមានទាំងសេវាសំរាប់អ្នកថ្លង់គ្រចៀក ។

- ទទួលសំភារៈព័ត៌មាន ជាភាសាផ្សេងៗ ឬជាទំរង់ផ្សេងទៀត និងការបោះពុម្ពជាទំហំធំ តាមសំណូមពរ ។

**អ្នកមានសិទ្ធិ ផ្តល់យោបល់ផ្លាស់ប្តូរ ចំពោះគំរោងសុខភាពរបស់យើង**

- ប្រាប់យើងនូវអ្វីៗដែលអ្នកមិនចូលចិត្ត អំពីគំរោងសុខភាពរបស់យើង ។
- ប្រាប់យើងនូវអ្វីៗដែលអ្នកមិនចូលចិត្ត អំពីការថែទាំដែលអ្នកទទួល ។
- សួរសំណួរ អំពីការសំរេចរបស់យើង ស្តីអំពីការថែទាំសុខភាពរបស់អ្នក ។
- ប្រាប់យើងនូវអ្វីៗដែលអ្នកមិនចូលចិត្ត អំពីក្រឹត្យក្រមរបស់យើង ស្តីអំពីសិទ្ធិ និងការទទួលខុសត្រូវ ។
- ស្នើសូមទៅក្រសួងសង្គមកិច្ច ឲ្យមានសវនាការរកយុត្តិធម៌ ។
- ស្នើសូមទៅក្រសួងចាត់ចែងសុខាភិបាល សំរាប់ការពិនិត្យពិច័យដោយវេជ្ជបណ្ឌិតឯករាជ្យ ។
- ជ្រើសរើសចាកចេញពីគំរោងសុខភាពរបស់យើង ។

## ឋានៈជាសមាជិកនៃគំរោងថែទាំសុខភាព តើការទទួលខុសត្រូវរបស់អ្នក មានអ្វីខ្លះ?

**យើងសង្ឃឹមថាអ្នកនឹងសហការជាមួយគ្រូពេទ្យរបស់អ្នក ជាដៃគូក្នុងការថែទាំសុខភាពរបស់អ្នក**

- ដាក់ណាត់ពេលជួប ជាមួយនឹងគ្រូពេទ្យរបស់អ្នក ក្នុងរយៈពេល 120 ថ្ងៃ នៃពេលបានក្លាយជាសមាជិកថ្មី សំរាប់ការប៉ាន់ប្រមាណសុខភាពជាលើកដំបូង ។
- ប្រាប់គ្រូពេទ្យរបស់អ្នក នូវអ្វីៗដែលគាត់ត្រូវការដឹង ដើម្បីព្យាបាលអ្នក ។
- ស្វែងយល់ឲ្យបានច្រើនបំផុត អំពីសុខភាពរបស់អ្នក ។
- ធ្វើតាមគំរោងការព្យាបាល ដែលអ្នក និងគ្រូពេទ្យរបស់អ្នកបានព្រមព្រៀង ។
- ធ្វើតាមនូវអ្វីៗដែលគ្រូពេទ្យប្រាប់អ្នក ដើម្បីថែទាំខ្លួនអ្នកឲ្យបានល្អ ។
- ធ្វើអ្វីៗដែលរក្សាអ្នកកុំឲ្យឈឺថ្កាត់ ។
- យកអត្តសញ្ញាណប័ណ្ណមកជាប់ខ្លួនអ្នក នៅពេលអ្នកទៅជួបគ្រូពេទ្យរបស់អ្នក ។
- ប្រព្រឹត្តទៅកាន់គ្រូពេទ្យ និងអ្នកថែទាំផ្សេងៗទៀត ដោយគោរព ។
- ប្រើបន្ទប់សង្គ្រោះភាពអាសន្ន សំរាប់តែភាពជាអាសន្នប៉ុណ្ណោះ ។ គ្រូពេទ្យរបស់អ្នក នឹងផ្តល់ការថែទាំសុខភាពសឹងតែទាំងអស់ដែលអ្នកត្រូវការ ។
- រាយការណ៍ពីការក្លែងបន្លំ នូវការថែទាំសុខភាព ។

**យើងចង់ឲ្យអ្នកយល់ដឹង អំពីគំរោងសុខភាពរបស់អ្នក ។**

- ត្រូវដឹង និងធ្វើតាមច្បាប់នានា នៃគំរោងសុខភាពរបស់អ្នក ។
- ត្រូវដឹងច្បាប់ដែលណែនាំគំរោងសុខភាពរបស់យើង និងសេវាដែលអ្នកទទួល ។
- ត្រូវដឹងថាយើងមិនអាចប្រព្រឹត្តមកលើអ្នកខុសពីគេ ពីព្រោះតែ អាយុ ភេទ ជាតិសាសន៍ ដើមកំណើត វប្បធម៌ សេចក្តីត្រូវការខាងភាសា លក្ខណៈការសេពសន្ថវៈ និង/ឬ សុខភាព ឡើយ ។